# របៀបពិនិត្យអ្នកជំងឺ

ជំពូកទី
៣

ដើម្បីស្វែងយល់អំពីសេចក្តីត្រូវការរបស់អ្នកជំងឺ ដំបូងអ្នកត្រូវសួរសំនួរសំខាន់ៗដល់អ្នកជំងឺសិន រួចទើបពិនិត្យគាត់ដោយប្រុងប្រយ័ត្ន។ អ្នកគួរពិនិត្យរកមើលរោគសញ្ញា និងសញ្ញាតម្ងួញផ្សេងៗ ដែលអាចជួយឲ្យអ្នកដឹងអំពីសភាពរបស់អ្នកជំងឺ និងប្រភេទជំងឺដែលគាត់អាចមាន។

ជានិច្ចកាល ត្រូវពិនិត្យអ្នកជំងឺនៅកន្លែងមានពន្លឺល្អ ជាពិសេសគឺនៅកន្លែងដែលមានពន្លឺព្រះអាទិត្យ ហើយមិនត្រូវពិនិត្យនៅក្នុងបន្ទប់ងងឹតជាដាច់ខាត។

មានបញ្ហាសំខាន់ៗមួយចំនួន ដែលត្រូវសួរនិងត្រូវពិនិត្យរកលើអ្នកដែលមានអ្នកជំងឺ។ បញ្ហាទាំងនេះរាប់បញ្ចូលទាំងអារម្មណ៍ដែលអ្នកជំងឺមាន ឬការត្អូញត្អែររបស់អ្នកជំងឺ(សញ្ញាតម្ងួញ) ព្រមទាំងបញ្ហាដែលអ្នកបានកត់សំគាល់ក្នុងពេលពិនិត្យអ្នកជំងឺនោះ(រោគសញ្ញា)។ រោគសញ្ញាទាំងអស់នេះអាចមានសារសំខាន់យ៉ាងខ្លាំង ជាពិសេសចំពោះទារក និងមនុស្សដែលមិនអាចនិយាយ។ នៅក្នុងសៀវភៅនេះ ពាក្យថា "រោគសញ្ញា" គឺត្រូវបានប្រើសំដៅទៅលើទាំងសញ្ញាតម្ងួញ និងរោគសញ្ញាដែលអ្នកបានកត់សំគាល់នៅពេលពិនិត្យអ្នកជំងឺ។

**នៅពេលដែលអ្នកពិនិត្យអ្នកជំងឺ ចូរកត់ត្រាទុកនូវរោគសញ្ញាដែលអ្នករកឃើញ ហើយរក្សាវាទុកសំរាប់បុគ្គលិកសុខាភិបាល ក្នុងករណីដែលគាត់ត្រូវការ** (ទំ.៤៤)។

## សំនួរ

ចាប់ផ្តើមដោយសួរអ្នកជំងឺអំពីស្ថានភាពជំងឺរបស់គាត់។ ត្រូវប្រាកដថាបានសួរសំនួរខាងក្រោមនេះ ៖

- តើបញ្ហាអ្វីដែលធ្វើទុក្ខអ្នកខ្លាំងបំផុតក្នុងពេលឥលូវនេះ?
- តើមានអ្វីដែលធ្វើឲ្យអ្នកមានអារម្មណ៍ធូរស្រាល ឬកាន់តែធ្ងន់ធ្ងរជាងមុន?
- តើជំងឺរបស់អ្នកចាប់ផ្តើមឡើងយ៉ាងដូចម្តេច និងនៅពេលណា?
- តើអ្នកធ្លាប់មានបញ្ហាដូចនេះ ពីមុនទេ? ឬមានអ្នកដទៃទៀតក្នុងគ្រួសារ ឬអ្នកជិតខាងមានបញ្ហានេះទេ?



បន្តសួរសំនួរផ្សេងៗទៀត ដើម្បីឲ្យដឹងយ៉ាងលម្អិតអំពីជំងឺនោះ។

ឧទាហរណ៍ ៖ ប្រសិនបើអ្នកជំងឺមានការឈឺចាប់ សួរគាត់ថា ៖

- តើឈឺនៅត្រង់កន្លែងណា? (សូមឲ្យគាត់ចង្អុលត្រង់កន្លែងដែលឈឺដោយប្រើម្រាមដៃតែមួយបានហើយ)
- តើឈឺជាប់រហូតឬ? ឬឈឺម្តងៗ?
- តើឈឺរបៀបដូចម្តេច (ដូចគេចាក់ ឬឈឺអួលៗ ឬឈឺផ្សាដូចរលាក)
- តើអ្នកអាចសំងំដេកបានទេ ពេលឈឺ?

ប្រសិនបើអ្នកជំងឺគឺជាទារកដែលមិនទាន់ចេះនិយាយ ត្រូវពិនិត្យរករោគសញ្ញានៃការឈឺចាប់របស់វា។ សំគាល់មើលចលនារបស់ទារក និងការយំរបស់វា។ (ឧទាហរណ៍ ៖ ជួនកាល ក្មេងដែលមានការឈឺចាប់នៅត្រចៀក អាចយកដៃវាទៅអេះនៅផ្នែកចំហៀងនៃក្បាលរបស់វា ឬចាប់ទាញត្រចៀករបស់វា)។

## ស្ថានភាពទូទៅនៃសុខភាព

មុនពេលប៉ះពាល់អ្នកជំងឺ ត្រូវសំឡឹងមើលគាត់ដោយប្រុងប្រយ័ត្ន។ សង្កេតមើលគាត់ ថាតើគាត់ឈឺឬខ្សោយ យ៉ាងណា គាត់ធ្វើចលនាយ៉ាងដូចម្ដេច គាត់ដកដង្ហើមដូចម្ដេច និងថាតើស្មារតីរបស់គាត់នៅដឹងច្បាស់ប៉ុនណា។ ត្រូវរកមើលរោគសញ្ញានៃការខ្វះជាតិទឹក(ទំ.១៥១) និងស្លុក(ទំ.៧៧)។

ចូរសង្កេតមើលថាតើអ្នកជំងឺមានបញ្ហាអាហារូបត្ថម្ភល្អឬទេ។ តើគាត់មានការស្រកទម្ងន់ឬទេ? នៅពេលដែលមនុស្សម្នាក់មានការស្រកទម្ងន់បន្តិចម្ដងៗក្នុងពេលយូរ នោះគាត់អាចមានជំងឺរ៉ាំរ៉ៃ (ជំងឺដែលកើតឡើងយូរមកហើយ)។

ជាមួយគ្នានេះដែរ ចូរសង្កេតមើលពណ៌របស់ភ្នែកនិងស្បែក។ ជួនកាលពណ៌នេះអាចប្រែប្រួល នៅពេលមនុស្សយើងមានជំងឺ។ (ស្បែកខ្មៅអាចបិទបាំងការប្រែប្រួលនៃពណ៌បាន។ ដូច្នេះត្រូវរកមើលផ្នែកណាមួយនៃរាងកាយដែលមានភាពស្លេកស្លាំង ដូចជានៅបាតដៃ ឬបាតជើង ក្រចកដៃ ឬផ្នែកខាងក្នុងនៃបបូរមាត់ និងត្របកភ្នែក)។

- ភាពស្លេកស្លាំងជាពិសេសនៅបបូរមាត់និងខាងក្នុងត្របកភ្នែក គឺជារោគសញ្ញានៃភាពស្លេកស្លាំង (ទំ.១២៤)។ ស្បែកក៏អាចក្លាយទៅជាមានពណ៌ស្រាលជាងមុន ដោយសារការមានជំងឺរបេង(ទំ.១៧៩) ឬជំងឺក្វាស្យូក័រ (ទំ.១១៣)។
- ការមានស្បែកពណ៌ប្រផេះ អាចជារោគសញ្ញានៃការគ្មានអាហារបរិភោគ(ទំ.១១២)។
- ស្បែកពណ៌ខៀវ ជាពិសេសបបូរមាត់និងក្រចកដៃមានពណ៌ខៀវ ឬប្រផេះ អាចមានន័យថាមានបញ្ហាធ្ងន់ធ្ងរ ដែលទាក់ទងជាមួយការដកដង្ហើម(ទំ.៧៩. ១៦៧ និង៣១៣) ឬជាមួយបេះដូង(ទំ.៣២៥)។ កុមារដែលសន្លប់ហើយមានស្បែកពណ៌ខៀវប្រផេះ នោះអាចជារោគសញ្ញានៃជំងឺគ្រុនចាញ់នៅខួរក្បាល(ទំ.១៨៦)។
- ស្បែកពណ៌សប្រផេះ ត្រជាក់ហើយសើម អាចមានន័យថាជារោគសញ្ញានៃស្លុក(ទំ.៧៧)។
- ស្បែកនិងភ្នែកពណ៌លឿង(ជំងឺលឿង) អាចបណ្ដាលមកពីការមានជំងឺនៅក្នុងថ្លើម(ជំងឺរលាកថ្លើម ទំ.១៧២ ជំងឺក្រិនថ្លើម ទំ.៣២៨ ជំងឺបូសថ្លើម ទំ.១៤៥) ឬមានជំងឺនៅក្នុងថង់ទឹកប្រម៉ាត់(ទំ.៣២៩)។ ជំងឺនេះក៏អាចកើតលើទារកដែលទើបសម្រាល និងលើទារកដែលមានជំងឺគ្រាប់ឈាមក្រហមដែរ(ទំ.២៧៤)។

ម៉្យាងទៀត ចូរពិនិត្យមើលស្បែកនៅពេលដែលមានពន្លឺចាំងឆ្លុះពីជ្រុងម្ខាងទៀតនៃស្បែកនោះ។ ការធ្វើនេះអាចបង្ហាញពីរោគសញ្ញាដំបូងបង្អស់ នៃការមានកន្ទួលក្រហមអ៊ុចៗនៃជំងឺកញ្ជ្រឹល នៅលើមុខរបស់កុមារដែលមានគ្រុនក្ដៅ។

## សីតុណ្ហភាព



ការស្ទង់សីតុណ្ហភាពរបស់អ្នកជំងឺ តែងតែជាការសំខាន់ណាស់ ទោះបីជាគាត់ហាក់ដូចជាគ្មានគ្រុនក្ដៅក៏ដោយ។ ប្រសិនបើមនុស្សម្នាក់មានជំងឺធ្ងន់ធ្ងរ គេត្រូវស្ទង់សីតុណ្ហភាពយ៉ាងតិច ៤ដងក្នុងមួយថ្ងៃ ហើយកត់ត្រាទុកឲ្យបានល្អ។



ប្រសិនបើគ្មានសីតុណ្ហមាត្រទេ អ្នកអាចស្ទង់សីតុណ្ហភាពបានដោយដាក់ខ្នងដៃរបស់អ្នកម្ខាងនៅលើថ្ងាសរបស់អ្នកជំងឺ ហើយម្ខាងទៀតដាក់លើថ្ងាសរបស់អ្នក ឬនរណាម្នាក់ដែលមានសុខភាពល្អ។ ប្រសិនបើអ្នកជំងឺនោះមានគ្រុនក្ដៅ នោះអ្នកនឹងមានអារម្មណ៍ថាមានសីតុណ្ហភាពខុសគ្នាជាមិនខាន។

វាគឺជាការសំខាន់ណាស់ដែលត្រូវស្វែងយល់ថាតើគ្រុនក្ដៅចាប់ផ្ដើមនៅពេលណា ចាប់ផ្ដើមយ៉ាងដូចម្ដេច មានរយៈពេលប៉ុន្មាន ហើយវាបាត់ទៅវិញយ៉ាងដូចម្ដេច។ ព័ត៌មានទាំងនេះអាចជួយឲ្យអ្នកកំណត់នូវប្រភេទជំងឺបាន។ ប៉ុន្តែមិនមែនគ្រប់ករណីនៃគ្រុនក្ដៅទាំងអស់សុទ្ធតែជាជំងឺគ្រុនចាញ់ទេ ទោះបីជាក្នុងប្រទេសខ្លះគេតែងតែធ្វើការព្យាបាលជំងឺនេះតែម្ដងក៏ដោយ។ ត្រូវចងចាំអំពីមូលហេតុផ្សេងៗទៀតរបស់វា។ ឧទាហរណ៍ ៖

- ជំងឺផ្ដាសាយធម្មតា និងការបង្ករោគដោយវីរុសផ្សេងៗទៀត (ទំ.១៦៣)។ ជាទូទៅ មានគ្រុនក្ដៅបន្តិចបន្តួច។
- ជំងឺគ្រុនពោះវៀនបណ្ដាលឲ្យមានគ្រុនក្ដៅ ដែលបន្តឡើងក្នុងរយៈពេល៥ថ្ងៃ។ ថ្នាំគ្រុនចាញ់មិនអាចជួយបានទេ។
- ជំងឺរបេងជួនកាលបណ្ដាលឲ្យមានគ្រុនក្ដៅបន្តិចបន្តួចនៅពេលល្ងាច។ ចំណែកនៅពេលយប់ អ្នកជំងឺច្រើនតែបែកញើស ហើយគ្រុនក្ដៅក៏ថយចុះដែរ។

# របៀបប្រើសីតុណ្ហមាត្រ

គ្រួសារនីមួយៗគប្បីមានសីតុណ្ហមាត្រមួយ។ វាស់សីតុណ្ហភាពរបស់អ្នកជំងឺបួនដងក្នុងមួយថ្ងៃ ហើយកត់ទុកជានិច្ច។

**របៀបមើលសីតុណ្ហមាត្រ** (ប្រើសីតុណ្ហមាត្រដែលមានកម្រិតអង្សាសង់ទីក្រាត គឺអង្សាសេ)៖




## របៀបវាស់សីតុណ្ហភាព



១. លាងសីតុណ្ហមាត្រជាមួយនឹងសាប៊ូនិងទឹក ឬជាមួយអាល់កុល។ រួចរលាស់វាឲ្យខ្លាំងៗ រហូតដល់ខ្សែពណ៌ទឹកប្រាក់ចុះ មកនៅក្រោម៣៦អង្សា។

២. ដាក់សីតុណ្ហមាត្រនេះ......

*ក្រោមអណ្តាត (បិទមាត់)*



*ឬនៅក្លៀក បើខ្វាចអ្នកជំងឺខាំសីតុណ្ហមាត្រ*



*ឬ ដាក់ចូលក្នុងរន្ធគូថ ប៉ុន្តែត្រូវប្រយ័ត្ន ចំពោះទារក (លាបទឹកឬលាបប្រេងរំអិលជាមុនសិន)*



៣. ទុកសីតុណ្ហមាត្រនៅកន្លែងដែលដាក់វាស់នោះរយៈពេល ៣ឬ៤នាទី។

៤. យកសីតុណ្ហមាត្រមកមើល។ (សីតុណ្ហភាពនៅក្លៀក អាចទាបជាងសីតុណ្ហភាពនៅក្នុងមាត់បន្តិច ឯសីតុណ្ហភាពក្នុងរន្ធគូទ អាចខ្ពស់បន្តិច)។

៥. លាងសីតុណ្ហមាត្រជាមួយសាប៊ូនិងទឹក។

***ចំណាំ ៖*** ចំពោះទារកដែលទើបសម្រាល ការមានសីតុណ្ហភាពខ្ពស់ **ឬទាបខុសពីធម្មតា** (ក្រោម៣៦អង្សា) អាចមានន័យថា មានការបង្ករោគធ្ងន់ធ្ងរ (ទំ.២៧៥)។

- ដើម្បីសិក្សាអំពីលក្ខណៈនៃគ្រុនក្តៅ សូមមើលទំ.២៦ ទៅ២៧។
- ដើម្បីសិក្សាអំពី តើត្រូវយ៉ាងដូចម្តេចនៅពេលមានគ្រុនក្តៅ សូមមើលទំ.៧៥។

# ការដកដង្ហើម

ត្រូវផ្តោតការយកចិត្តទុកពិសេសទៅលើការដកដង្ហើមរបស់អ្នកជំងឺ គឺអំពីជម្រៅដង្ហើម( ជ្រៅៗ ឬសើៗ ) ចង្វាក់ដង្ហើម ( ដកដង្ហើមញាប់ឬយឺត ) និងការពិបាកក្នុងការដកដង្ហើម។ សង្កេតមើលថាតើប្រអប់ទ្រូងទាំងសងខាងរបស់គាត់ មានចលនាស្មើគ្នាទេនៅពេលដែលគាត់ដកដង្ហើម។

បើអ្នកមាននាឡិកា ឬប្រដាប់វាស់ពេលវេលាងាយៗ ចូររាប់ចង្វាក់ដង្ហើមក្នុងមួយនាទី( ក្នុងពេលដែលអ្នកជំងឺនៅស្ងៀម )។ ការដកដង្ហើមពី១២ទៅ២០ដងក្នុងមួយនាទី គឺជាចង្វាក់ដង្ហើមធម្មតារបស់មនុស្សពេញវ័យ និងកុមារធំៗ។ ការដកដង្ហើមរហូតដល់៣០ដងក្នុងមួយនាទី គឺជាចង្វាក់ដង្ហើមធម្មតារបស់កុមារ ហើយ៤០ដង គឺធម្មតាសំរាប់ទារក។ អ្នកដែលមានគ្រុនក្តៅខ្លាំង ឬជំងឺប្រព័ន្ធដង្ហើមធ្ងន់ធ្ងរ( ដូចជាជំងឺរលាកសួត ) ដកដង្ហើមញាប់ជាងធម្មតា។ ការដកដង្ហើមសើៗ លើសពី៤០ដងក្នុងមួយនាទី ចំពោះមនុស្សពេញវ័យ ឬ៦០ដង ចំពោះកុមារតូចៗ ជាទូទៅមានន័យថា មានជំងឺរលាកសួត។

ស្តាប់សំឡេងដកដង្ហើមដោយប្រុងប្រយ័ត្ន។ ឧទាហរណ៍ ៖

- សំឡេងដូចហួច ឬថ្ងូរខ្យល់ និងការពិបាកដកដង្ហើមចេញ អាចមានន័យថាជាជំងឺហឺត( ទំ.១៦៧ )។
- សំឡេងគ្រូកក្រកៗ ឬសូរស្រមុក និងការពិបាកដកដង្ហើមលើមនុស្សសន្លប់ អាចមានន័យថាអណ្តាត ស្លេស ( ទឹករំអិល ឬខ្ទុះ ) ឬអ្វីផ្សេងៗបានជាប់ស្ទះក្នុងបំពង់ខ្យល់ ហើយរារាំងខ្យល់មិនឲ្យចេញចូលគ្រប់គ្រាន់។

រកមើលកន្លែងដែលផតចូលក្នុង នៅតាមចន្លោះឆ្អឹងជំនីរ និងនៅត្រង់មុំរបស់កនៅពេលដែលគាត់ដកដង្ហើមចូល។ បញ្ហានេះមានន័យថាខ្យល់ពិបាកឆ្លងចូល។ សូមគិតអំពីការដែលអាចមានវត្ថុអ្វីជាប់នៅក្នុងបំពង់ក( ទំ.៧៩ ) មានជំងឺរលាកសួត( ទំ.១៧១ ) ជំងឺហឺត( ទំ.១៦៧ ) ឬមានជំងឺរលាកទងសួត( ទំ.១៧០ )។

បើអ្នកជំងឺមានក្អក សូមសួរថាតើវារំខានដំណេករបស់គាត់ទេ។ ស្រាវជ្រាវមើលថាតើគាត់ក្អកមានស្លេសទេ មានប៉ុន្មាន ពណ៌អ្វី ហើយមានលាយឈាមឬទេ។

# ជីពចរ ( ចង្វាក់បេះដូង )

*ដើម្បីរាប់ជីពចរមនុស្សម្នាក់ គេដាក់ម្រាមដៃនៅលើ កដៃ ដូចបង្ហាញខាងក្រោម ( មិនត្រូវយកមេដៃទៅស្ទាបជីពចរទេ )*



*ប្រសិនបើអ្នកស្ទាបរកជីពចរ នៅកដៃមិនឃើញទេ ស្ទាបនៅកញ្ចឹងក នៅពីចំហៀងបំពង់សំឡេង*



*ឬដាក់ត្រចៀកលើទ្រូងផ្ទាល់ ហើយស្តាប់ចង្វាក់បេះដូង ( ឬប្រើស្តេតូស្កូប ប្រសិនបើមាន )*



យកចិត្តទុកដាក់លើកម្លាំង ចង្វាក់ និងភាពទៀងទាត់របស់ជីពចរ។ បើអ្នកមាននាឡិកា រាប់ចំនួនជីពចរក្នុងមួយនាទី។

**ចំនួនជីពចរធម្មតារបស់មនុស្សនៅពេលសម្រាក**

មនុស្សពេញវ័យ..........................ពី៦០ទៅ៨០ក្នុងមួយនាទី

កុមារ........................................ពី៨០ទៅ១០០ក្នុងមួយនាទី

ទារក........................................ពី១០០ទៅ១៤០ក្នុងមួយនាទី

ជីពចរតែងតែដើរញាប់នៅពេលគេធ្វើលំហាត់ប្រាណ និងនៅពេលដែលគេមានអារម្មណ៍រសាប់រសល់ ភ័យខ្លាច ឬមានគ្រុនក្ដៅ។ ជាទូទៅ ជីពចរកើន២០ដងក្នុងមួយនាទី នៅពេលគ្រុនក្ដៅឡើង១អង្សាសេ ។

នៅពេលមនុស្សម្នាក់ឈឺធ្ងន់ ត្រូវរាប់ជីពចរឲ្យបានញឹកញាប់ ហើយកត់ទុកជាមួយនឹងសីតុណ្ហភាព និងចង្វាក់ដង្ហើម។

វាជាការសំខាន់ណាស់ដែលត្រូវសង្កេតអំពីការប្រែប្រួលនៃចង្វាក់ជីពចរ។ ឧទាហរណ៍ ៖

- ជីពចរខ្សោយហើយញាប់ អាចមានន័យថា អ្នកជំងឺស្ថិតក្នុងស្ថានភាពស្លុក(ទំ.៧៧)។
- ជីពចរដើរយ៉ាងលឿន យ៉ាងយឺត ឬមិនទៀងទាត់ អាចមានន័យថា មានបញ្ហាបេះដូង(ទំ.៣២៥)។
- អ្នកដែលមានគ្រុនក្ដៅ ហើយជីពចរដើរយឺត នោះអាចជារោគសញ្ញានៃជំងឺគ្រុនពោះវៀន(ទំ.១៨៨)។

## ភ្នែក

ពិនិត្យមើលពណ៌របស់ផ្នែកសនៃភ្នែក។ តើវាមានពណ៌ធម្មតា ពណ៌ក្រហម(ទំ.២១៩) ឬលឿង? ម្យ៉ាងទៀត ត្រូវពិនិត្យមើលពីការប្រែប្រួលនៃគំហើញរបស់អ្នកជំងឺ។

ឲ្យអ្នកជំងឺធ្វើចលនាគ្រាប់ភ្នែកយឺតៗ ឡើងលើ ចុះក្រោម និងទៅខាងៗ ម្ខាងម្ដងៗ។ ការមានចលនាកន្ត្រាក់ៗ ឬមិនស្មើ អាចជារោគសញ្ញានៃការខូចខួរក្បាល។

សង្កេតមើលទំហំនិងពណ៌របស់កូនក្រមុំភ្នែក(ផ្នែកខ្មៅនៅកណ្ដាលភ្នែក)។ ប្រសិនបើវារីកធំខ្លាំង វាអាចមានន័យថា អ្នកជំងឺកំពុងស្ថិតក្នុងស្ថានភាពស្លុក(ទំ.៧៧)។ ប្រសិនជាវារីកធំខ្លាំងឬរួមតូចខ្លាំង នោះវាអាចជាការពុល ឬជាឥទ្ធិពលរបស់ថ្នាំអ្វីមួយ។ ប្រសិនបើមានស្រទាប់សៗ វាអាចមានន័យថាជាភ្នែកឡើងបាយ(ទំ.២២៥) ឬជាមហារីក។

ពិនិត្យមើលភ្នែកទាំងពីរ ហើយរកមើលបើមានភាពខុសគ្នា ជាពិសេសមើលទំហំនៃកូនក្រមុំភ្នែក។



ភាពខុសគ្នាយ៉ាងខ្លាំងនៃទំហំរបស់កូនក្រមុំភ្នែកទាំងពីរ តែងតែជាស្ថានភាពដែលត្រូវការការសង្គ្រោះបន្ទាន់។

- បើភ្នែកដែលមានកូនក្រមុំភ្នែករីកធំនោះ មានការឈឺចាប់យ៉ាងខ្លាំងរហូតដល់ធ្វើឲ្យក្អួត នោះអ្នកជំងឺប្រហែលជាមានជំងឺគ្លូកូម(ទំ.២២២)។
- បើភ្នែកដែលមានកូនក្រមុំភ្នែករួមតូចនោះ មានការឈឺចាប់យ៉ាងខ្លាំង នោះអ្នកជំងឺប្រហែលជាមានជំងឺរលាកប្រស្រីភ្នែក (ទំ.២២១) ដែលជាជំងឺដ៏ធ្ងន់ធ្ងរមួយ។
- បើមនុស្សដែលសន្លប់ ឬមនុស្សដែលទើបមានរបួសក្បាល មានទំហំកូនក្រមុំភ្នែកខុសគ្នា នោះអាចមានន័យថា មានការខូចខួរក្បាល។ វាក៏អាចមានន័យថាជាជំងឺដាច់សរសៃឈាមខួរក្បាលដែរ(ទំ.៣២៧)។

**ត្រូវប្រៀបធៀបទំហំកូនក្រមុំភ្នែកទាំងពីររបស់អ្នកដែលសន្លប់ ឬអ្នកដែលមានរបួសក្បាល ជានិច្ច។**

## ត្រចៀក បំពង់ក និងច្រមុះ



**ត្រចៀក ៖** ពិនិត្យរកមើលសញ្ញានៃការឈឺចាប់ និងការបង្ករោគនៅក្នុងត្រចៀក ជាពិសេសចំពោះកុមារដែលមានគ្រុនក្តៅ ឬមានជំងឺផ្តាសាយ។ ទារកដែលយំច្រើន ហើយទាញត្រចៀករបស់វាជាញឹកញាប់ ភាគច្រើនមានការបង្ករោគនៅក្នុងត្រចៀក(ទំ.៣០៩)។

ទាញត្រចៀកដោយថ្នមៗ បើវាធ្វើឲ្យមានការឈឺចាប់កាន់តែខ្លាំងឡើង នោះការបង្ករោគប្រហែលជាស្ថិតនៅក្នុងរន្ធត្រចៀក។ ម៉្យាងទៀត រកមើលស្នាមក្រហម ឬខ្ទុះនៅក្នុងត្រចៀក។ គេអាចប្រើភ្លើងឆ្នុះ ឬពិលតូចមួយជាជំនួយ។ ប៉ុន្តែមិនត្រូវយកឈើ លួស ឬវត្ថុរឹងផ្សេងៗ ទៅឆ្កិះផ្នែកខាងក្នុងត្រចៀកទេ។

ពិនិត្យមើលថាតើអ្នកជំងឺស្តាប់ឮច្បាស់ទេ ឬត្រចៀកម្ខាងឮតិចជាងម្ខាងទៀត។ ត្រដុសមេដៃនិងម្រាមដៃរបស់អ្នកនៅជិត ត្រចៀករបស់គាត់ ដើម្បីមើលថាតើគាត់អាចស្តាប់ឮឬទេ។ ចំពោះការថ្លង់ និងការហ៊ឹងត្រចៀក អានទំព័រទី៣២៧។

**បំពង់ក និងមាត់ ៖** អ្នកអាចប្រើពិល ឬពន្លឺថ្ងៃ ដើម្បីពិនិត្យមាត់និងបំពង់ក។ ដើម្បីពិនិត្យ អ្នកអាចយកដងស្លាបព្រាសង្កត់អណ្តាត ឬឲ្យអ្នកជំងឺនិយាយថា "អាំ..."។ ពិនិត្យមើលថាតើបំពង់កក្រហមឬទេ តើកន្ទើត (សាច់ពីរដុំក្នុងបំពង់កនេះ) ហើមឬទេ ឬមានដុំខ្ទុះឬទេ(ទំ.៣០៩)។ ម៉្យាងទៀត ពិនិត្យមាត់រកមើលដំបៅ ការរលាកអញ្ចាញធ្មេញ ដំបៅអណ្តាត ធ្មេញពុក ឬមានបូស និងបញ្ហាផ្សេងៗទៀត (ជំពូកទី១៧)។

**ច្រមុះ ៖** តើច្រមុះមានហៀរសំបោរ ឬតឹងទេ? (សង្កេតមើលការដកដង្ហើមរបស់ទារកតាមច្រមុះ)។ បញ្ចាំងភ្លើងចូលក្នុងច្រមុះ ហើយរកមើលសំបោរ ខ្ទុះ ឬឈាម និងរកមើលស្នាមក្រហម ហើម ឬក្លិនស្អុយ។ រកមើលរោគសញ្ញានៃជំងឺក្នុងច្រមុះ ឬជំងឺតឹងច្រមុះ(ទំ.១៦៥)។

## ស្បែក

វាជាការសំខាន់ណាស់ដែលត្រូវពិនិត្យមើលរាងកាយទាំងមូលរបស់អ្នកជំងឺ ទោះបីជាស្ថានភាពរបស់ជំងឺនោះ ហាក់ដូចជាស្រាលក៏ដោយ។ ចំពោះទារក និងកុមារ គួរដោះសំលៀកបំពាក់ចេញឲ្យអស់។ ពិនិត្យមើលដោយយកចិត្តទុកដាក់លើគ្រប់ភាពមិនប្រក្រតីទាំងអស់ ដែលរួមមាន ៖

- ដំបៅ របួស ឬស្នាមមុតផ្សេងៗ
- កន្ទួល ឬស្នាមជាំ
- ស្នាមអុចៗ ស្នាមរលាត់ ឬស្លាកស្នាមផ្សេងៗខុសពីធម្មតា
- រលាក (រោគសញ្ញានៃការបង្ករោគ ដូចជា ក្រហម ក្តៅ ឈឺចាប់ និងហើម)
- ការហើម ឬប៉ោង
- ការហើមកូនកណ្តុរ(ដុំតូចៗនៅក ក្លៀក ឬក្រលៀន សូមមើលទំ.៨៨)
- ភាពមិនធម្មតានៃកូនកណ្តុរ
- សក់ស្តើងមិនប្រក្រតី ឬជ្រុះសក់ ឬបាត់បង់ពណ៌ ឬស្រអាប់(ទំ.១១២)
- ជ្រុះរោមចិញ្ចើម (ជំងឺឃ្លង់? ទំ.១៩១)



ចំពោះកុមារតូចៗ ត្រូវពិនិត្យមើលនៅចន្លោះកំប៉េះគូទ ម្តុំប្រដាប់បន្តពូជ ចន្លោះម្រាមដៃ ម្រាមជើង ខាងក្រោយត្រចៀក និងសក់ក្បាល (រកមើលចៃ កមរមាស់ ស្រែង កន្ទួល និងដំបៅ)។

ដើម្បីសំគាល់អំពីបញ្ហាផ្សេងៗនៃស្បែក អានទំព័រ១៩៦-១៩៨។

# ពោះ

ប្រសិនបើមនុស្សម្នាក់ឈឺពោះ ត្រូវព្យាយាមរកកន្លែងពិតប្រាកដនៃការឈឺចាប់នោះ។

ស្រាវជ្រាវមើលថាតើវាជាការឈឺជាប់រហូត ឬវាកើតឡើងភ្លាមៗ ហើយក៏បាត់ទៅវិញ ដូចជា ការឈឺចុក ឬការចុកពោះ។

នៅពេលអ្នកពិនិត្យពោះ ដំបូងត្រូវរកមើលក្រែងមានកន្លែងហើម ឬមានដុំពកខុសធម្មតា។

ទីកន្លែងពិតប្រាកដនៃការឈឺចាប់ តែងតែជាសញ្ញាដែលអាចប្រាប់ពីមូលហេតុរបស់វា (សូមអានទំព័របន្ទាប់)។

*ដំបូងឲ្យអ្នកជំងឺយកម្រាមដៃមួយ ចង្អុលទៅកន្លែងឈឺ*



*បន្ទាប់មក ចាប់ផ្ដើមនៅលើផ្នែកម្ខាងទៀតនៃកន្លែងដែលគាត់បានចង្អុល រួចសង្កត់ថ្នមៗនៅគ្រប់ផ្នែកនៃពោះ ដើម្បីរកកន្លែងដែលមានការឈឺចាប់ខ្លាំងជាងគេបំផុត។*



ពិនិត្យមើលថា តើពោះទន់ឬរឹង និងមើលថា តើអ្នកជំងឺអាចបន្ធូរសាច់ដុំពោះរបស់គាត់បានឬទេ។ ពោះដែលរឹងខ្លាំងអាចមានន័យថាមានបញ្ហាស្រួចស្រាល់ក្នុងពោះ ដែលអាចជាជំងឺរលាកខ្នែងពោះវៀន ឬជំងឺរលាកស្រោមពោះ(ទំ.៩៤)។

ប្រសិនបើអ្នកសង្ស័យថាមានជំងឺរលាកស្រោមពោះ ឬជំងឺរលាកខ្នែងពោះវៀន សូមធ្វើតេស្ដ៏មើលការឈឺចាប់ ដូចដែលបានរៀបរាប់នៅទំព័រទី៩៥។

ស្ទាបរកដុំមិនធម្មតា និងកន្លែងដែលរឹង នៅក្នុងពោះ។

ប្រសិនបើអ្នកជំងឺមានការឈឺចាប់ជាប់ជានិច្ចនៅក្រពះ ដោយមានក្អួតចង្អោរ ហើយមិនអាចបន្ទោរបង់លាមកបាន ចូរដាក់ត្រចៀកអ្នក (ឬស្ដេតូស្កូប) នៅលើពោះ ដូចរូបភាពនេះ ៖



*ស្ដាប់សំឡេងគូរនៅក្នុងពោះវៀន ។ ក្នុងរយៈពេល ពីរនាទី បើពុំមានលឺអ្វីទេ នោះជាសញ្ញាគ្រោះថ្នាក់ហើយ ។ (មើលការសង្គ្រោះបន្ទាន់សំរាប់ករណីមានបញ្ហាពោះវៀន ទំ.៩៣)*

**ពោះដែលស្វាត់គឺប្រៀបដូចជាផ្លែដែលមិនព្រួស!! ចូរប្រយ័ត្ន!!**

រូបភាពទាំងនេះបង្ហាញអំពីផ្នែកផ្សេងៗនៃពោះ ដែលតែងតែមានការឈឺចាប់នៅពេលមនុស្សម្នាក់មានបញ្ហាដូចខាងក្រោមនេះ

ដំបៅក្រពះ (ទំ.១២៨)



ឈឺនៅចុងដង្ហើម

រលាកខ្នែងពោះវៀន (ទំ.៩៤)



ដំបូង ឈឺត្រង់នេះ

បន្ទាប់មកឈឺត្រង់នេះវិញ

ថង់ទឹកប្រមាត់ (ទំ.៣២៩)



ការឈឺចាប់ចាក់ទៅខ្នង

ថ្លើម (ទំ.១៧២, ១៤៤ និង១២៨)



ឈឺត្រង់កន្លែងនេះ ពេលខ្លះឈឺរាលដាលដល់ទ្រូង

ប្រព័ន្ធទឹកនោម (ទំ.២៣៤) ឈឺនៅផ្នែកកណ្តាល ឬក្រោមនៃខ្នង ហើយតែងតែរាលដាលទៅជុំវិញចង្កេះរហូតដល់ផ្នែកខាងក្រោមនៃពោះ



បំពង់ទឹកនោម

ប្លោកនោម

ការបង្កការរលាក ឬការមានដុំនៅអូវែ ឬមានគភ៌ក្រៅស្បូន (ទំ.២៨០)

ឈឺនៅផ្នែកម្ខាង ឬទាំងសងខាងនៃពោះ ជួនកាលរាលដាលទៅខ្នង



***សំគាល់៖*** ចំពោះមូលហេតុផ្សេងៗនៃការឈឺចាប់នៅខ្នង សូមមើលទំព័រ១៧៣។

# សាច់ដុំ និងសរសៃប្រសាទ

ប្រសិនបើមាននរណាម្នាក់ត្អូញត្អែរអំពីការស្ពឹក ខ្សោយ ឬបាត់បង់ការគ្រប់គ្រងលើផ្នែកណាមួយនៃរាងកាយ ឬប្រសិនបើអ្នកចង់ពិនិត្យមើល ៖ ចូរសង្កេតមើលការដើរ និងការធ្វើចលនាផ្សេងៗរបស់គាត់។ ឲ្យគាត់ឈរ អង្គុយ ឬដេកឲ្យត្រង់ខ្លួន រួចប្រៀបធៀបខ្លួនគាត់ទាំងសងខាងដោយយកចិត្តទុកដាក់។

**មុខ ៖** ឲ្យគាត់សើច ចងចិញ្ចើម បើកភ្នែកឲ្យធំ ហើយបិទឲ្យជិត។ ចូរសង្កេតមើលថាតើមុខម្ខាងមានធ្លាក់ ឬមានសភាពខ្សោយឬទេ?



ប្រសិនបើបញ្ហានេះកើតឡើងយឺតៗឬភ្លាមៗ ចូរគិតទៅដល់ការមានរបួសក្បាល(ទំ.៩១) ការដាច់សរសៃឈាមខួរក្បាល(ទំ.៣២៧) ឬការខូចសាច់ដុំមុខ(ទំ.៣២៧)។

ប្រសិនបើបញ្ហានេះកើតឡើងយឺតៗ នោះប្រហែលជាមានដុំក្នុងខួរក្បាល។ ចូររកជំនួយពីគ្រូពេទ្យ។

ជាមួយគ្នានេះដែរ ត្រូវពិនិត្យអំពីចលនាធម្មតារបស់ភ្នែក ទំហំកូនក្រមុំភ្នែក (ទំ.២១៧) និងគំហើញនៃភ្នែករបស់គាត់។

**ដៃនិងជើង ៖** រកមើលបើមានការស្រកសាច់ដុំ។ សំគាល់ ឬវាស់ភាពខុសគ្នានៃទំហំរបស់ដៃ និងជើង។

*ឲ្យគាត់ច្របាច់ម្រាមដៃអ្នកទាំងសងខាង ដើម្បីប្រៀបធៀបកម្លាំងនៃដៃរបស់គាត់។*



*រុញនិងទាញជើងរបស់គាត់ ទល់នឹងដៃរបស់អ្នក។*





*អ្នកអាចប្រើខ្សែដើម្បីវាស់ទំហំវង់ដៃ និងជើង មើលថាតើមានភាពខុសគ្នាឬទេ។*

*ឲ្យគាត់សណ្តូកដៃឲ្យត្រង់ ហើយបង្វិលឡើងលើ និងចុះក្រោម*



*សង្កេតមើលក្រែងមានភាពទន់ខ្សោយ ឬញ័រ*



*ឲ្យគាត់ដេកសណ្តូកជើង ហើយលើកជើងគាត់ម្ខាង បន្ទាប់មកម្ខាងទៀត*

ពិនិត្យមើលលក្ខណៈនៃការដើរ និងការធ្វើចលនារបស់គាត់។ ប្រសិនបើការស្រកសាច់ដុំ ឬភាពទន់ខ្សោយ មាននៅលើរាងកាយទាំងមូល សូមគិតទៅដល់បញ្ហាកង្វះអាហារូបត្ថម្ភ(ទំ.១១២) ឬមានជំងឺរ៉ាំរ៉ៃ ដូចជាជំងឺរបេង ជាដើម។

ប្រសិនបើការស្រកសាច់ដុំ ឬភាពទន់ខ្សោយ មាននៅកន្លែងផ្សេងៗគ្នា ឬមានខ្លាំងនៅតែម្ខាង ចំពោះកុមារ សូមគិតជាដំបូងទៅដល់ជំងឺស្វិតដៃជើង (ទំ.៣១៤) ចំពោះមនុស្សពេញវ័យ សូមគិតទៅដល់បញ្ហាឆ្អឹងខ្នង របួសឆ្អឹងខ្នងឬក្បាល ឬការដាច់សរសៃឈាមក្នុងខួរក្បាល។

ចំពោះព័ត៌មានបន្ថែមអំពីការធ្វើតេស្តសាច់ដុំនិងការពិនិត្យរាងកាយនៃមនុស្សពិការ សូមមើល ***កុមារពិការ*** នៅជំពូកទី៤។

## ការពិនិត្យរកមើលភាពរឹង ឬភាពតឹងនៃសាច់ដុំនានា



- បើថ្គាមរឹង ឬហាមិនបាន សូមសង្ស័យទៅលើជំងឺតេតាណូស(ទំ.១៨២) ឬមានការបង្ករោគធ្ងន់ធ្ងរនៅក្នុងបំពង់ក(ទំ.៣០៩) ឬនៅធ្មេញ(ទំ.២៣១)។ ប្រសិនបើបញ្ហារបស់គាត់ចាប់ផ្ដើមឡើងបន្ទាប់ពីគាត់ស្វាប ឬបន្ទាប់ពីមានការប៉ះទង្គិចត្រង់ថ្គាម នោះគាត់ប្រហែលជាភ្លាត់ថ្គាម។

- ចំពោះកុមារដែលឈឺធ្ងន់ បើរឹងកឬរឹងឆ្អឹងខ្នង ហើយកោងទៅក្រោយ សូមសង្ស័យទៅលើជំងឺរលាកស្រោមខួរ។ បើក្បាលមិនអាចបត់ទៅមុខបាន ឬមិនអាចដាក់ចន្លោះក្បាលជង្គង់បាន នោះអាចជាជំងឺរលាកស្រោមខួរមែនទែនហើយ(ទំ.១៨៥)។



ជំងឺរលាកស្រោមខួរ

- បើកុមារមានការរឹងសាច់ដុំខ្លះជាញឹកញាប់ ហើយមានចលនាចំលែកៗ ឬកន្ត្រាក់ៗ នោះគាត់ប្រហែលជាមានបញ្ហាកន្ត្រាក់របស់សាច់ដុំ (ទំ.៣២០)។

- បើចលនាប្លែកៗ ឬកន្ត្រាក់ៗនោះកើតឡើងភ្លាមៗ ដោយមានការបាត់បង់ស្មារតីផង នោះគាត់ប្រហែលជាមានការប្រកាច់(ទំ.១៧៨)។ បើការប្រកាច់កើតឡើងជាញឹកញាប់ សូមគិតដល់ជំងឺឆ្កួតជ្រូក។ បើវាកើតឡើងនៅពេលគាត់មានជំងឺ នោះប្រហែលបណ្ដាលមកពីការមានគ្រុនក្ដៅខ្លាំង(ទំ.៧៦) ឬការខ្សោះជាតិទឹក(ទំ.១៥១) ឬជំងឺតេតាណូស(ទំ.១៨២) ឬជំងឺរលាកស្រោមខួរ(ទំ.១៨៥)។




ដើម្បីធ្វើតេស្ដមើលរ៉េផ្លេចរបស់អ្នកជំងឺ នៅពេលដែលអ្នកសង្ស័យថាមានជំងឺតេតាណូស សូមមើលទំព័រ១៨៣។

## ដើម្បីពិនិត្យមើលការបាត់បង់ញាណដឹងនៅដៃ ជើង ឬផ្នែកដទៃទៀតនៃរាងកាយ

សូមឲ្យអ្នកជំងឺយកដៃបាំងភ្នែក។ ប៉ះឬច្បិចលើស្បែកថ្មមៗជាច្រើនកន្លែងផ្សេងៗគ្នា។ ឲ្យគាត់ឆ្លើយ "បាទ ឬចាស៎" នៅពេលដែលគាត់ដឹងថាមានគេប៉ះគាត់។



- ការបាត់បង់ញាណដឹងនៅចំណុច ឬជិតចំណុចស្នាមសន្លាកនៅលើរាងកាយ អាចជាជំងឺឃ្លង់(ទំ.១៩១)។

- ការបាត់បង់ញាណដឹងនៅដៃទាំងពីរ ឬជើងទាំងពីរ អាចបណ្ដាលមកពីជំងឺទឹកនោមផ្អែម(ទំ.១២៧) ឬជំងឺឃ្លង់។

- ការបាត់បង់ញាណដឹងតែម្ខាង អាចបណ្ដាលមកពីបញ្ហាឆ្អឹងខ្នង(ទំ.១៧៤) ឬមានរបួសឆ្អឹងខ្នង។